EMBASSY OF JAPAN
IN THE KINGDOM OF CAMBODIA

# PRESS RELEASE

No. 5PR-25/EoJ 5 February 2025

## Japan Provides US$1,302,539 for Landmines, Unexploded Ordnances and Cluster Munition Clearance

The Government of Japan will provide US$1,302,539 in total for a recipient organization under the framework, *the Grant Assistance for Japanese NGO Projects*. The Grant Contract was signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representative of the recipient, to carry out the following projects:

1. 'Promoting Reconstruction Support with Demining in Banteay Meanchey: PRDB'' (US$654,402)
Recipient: Japan Mine Action Service (JMAS)
In this project, JMAS will clear 100 ha of landmines and unexploded ordnances (UXOs) contaminated areas while transferring efficient and safe clearance mines and UXOs methods to Cambodian Mine Action Centre (CMAC). The project will also disseminate landmine risk avoidance education. Moreover, farmers will be given opportunities to learn rice cultivation techniques and develop model farms on the mine cleared land.

2. 'Promoting Reconstruction Support with Cluster munitions disposal in Stung Treng:PRCS' (US$648,137)
Recipient: Japan Mine Action Service (JMAS)
In this project, JMAS will demine 240 ha of cluster munition contaminated areas while instructing the Cambodian Mine Action Centre (CMAC) on efficient and safe cluster munition clearance methods. In addition, the project will provide not only landmine risk avoidance education for local residents but also agricultural technology and management for farmers.

*The Grant Assistance for Japanese NGO Projects* started in Cambodia in 2002 to support activities by Japanese NGOs to help Cambodia's reconstruction and development efforts at the grassroots level. Since 2002, the Government of Japan has provided nearly US$60 million for over 160 projects, mainly in the field of primary education, health, agriculture and mine

clearance in Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161*
*Email:* eco.jpn@pp.mofa.go.jp
*Website: http://www.kh.emb-japan.go.jp*

ស្ថានទូតជប៉ុន
ប្រចាំព្រះរាជាណាចក្រកម្ពុជា

សេចក្តីប្រកាសព័ត៌មាន

លេខ 5PR-25/EoJ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៥

**<u>ជប៉ុនផ្តល់ថវិកាចំនួន ១,៣០២,៥៣៨ ដុល្លារអាមេរិក</u>**

**<u>សម្រាប់ការបោសសម្អាតគ្រាប់មីន យុទ្ធភណ្ឌមិនទាន់ផ្ទុះ និងគ្រាប់បែកចង្កោម</u>**

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **១,៣០២,៥៣៨ ដុល្លារអាមេរិក** ដល់ស្ថាប័នទទួលជំនួយមួយ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយ សម្រាប់អនុវត្តគម្រោងខាងក្រោម៖

**<u>១.គម្រោងគាំទ្រការស្តាបនាឡើងវិញជាមួយការបោសសម្អាតមីននៅខេត្តបន្ទាយមានជ័យ ហៅកាត់ថាគម្រោង PRDB (ថវិកាចំនួន ៦៥៤,៤០២ ដុល្លារអាមេរិក)</u>**

**<u>ស្ថាប័នទទួលជំនួយ៖ អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS)</u>**

នៅក្នុងគម្រោងនេះ អង្គការ JMAS នឹងបោសសម្អាតតំបន់ដែលមានគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះចំនួន ១០០ហិចតា និងផ្ទេរវិធីសាស្ត្រដែលមានសក្តិសិទ្ធភាព និងសុវត្ថិភាព ក្នុងការបោសសម្អាតគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ទៅដល់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC)។ គម្រោងនេះ ក៏នឹងផ្តល់ការអប់រំអំពីការការបញ្ចៀសពីហានិភ័យនៃគ្រាប់មីនផងដែរ។ បន្ថែមពីនេះ កសិករនឹងទទួលបានឱកាសសិក្សាអំពីបច្ចេកទេសដាំដុះស្រូវ និងបង្កើតកសិដ្ឋានគំរូនៅលើទីតាំងដីដែលបោសសម្អាតមីនរួចរាល់។

**<u>២.គម្រោងគាំទ្រការស្តាបនាឡើងវិញជាមួយការបោសសម្អាតគ្រាប់បែកចង្កោមនៅខេត្តស្ទឹងត្រែង ហៅកាត់ថាគម្រោង PRCS (ថវិកាចំនួន ៦៤៨,១៣៧ ដុល្លារអាមេរិក)</u>**

**<u>ស្ថាប័នទទួលជំនួយ៖ អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS)</u>**

នៅក្នុងគម្រោងនេះ អង្គការ JMAS នឹងបោសសម្អាតតំបន់ដែលមានគ្រាប់បែកចង្កោមចំនួន ២៤០ហិចតា និងបង្រៀនមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) អំពីវិធីសាស្ត្រដែលមានសក្តិសិទ្ធភាព និងសុវត្ថិភាព ក្នុងការបោសសម្អាតគ្រាប់បែកចង្កោម។ មិនតែប៉ុណ្ណោះ គម្រោងនេះ នឹងផ្តល់ការអប់រំអំពីការការបញ្ចៀសពីហានិភ័យនៃគ្រាប់មីន ដល់ប្រជាជនមូលដ្ឋាន និងបណ្តុះបណ្តាលកសិករអំពីការគ្រប់គ្រង និងបច្ចេកវិទ្យាកសិកម្ម។

ជំនួយឥតគិតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២ មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៦០លាន ដុល្លារអាមេរិក ដល់គម្រោងចំនួន ១៦០ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតបឋមសិក្សា វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

**សុន្ទរកថារបស់ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យា**
**ផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន**
**ថ្ងៃពុធ ទី០៥ ខែកុម្ភៈ ឆ្នាំ២០២៥**

**គម្រោងគាំទ្រការស្តាបនាឡើងវិញជាមួយការបោសសម្អាតមីននៅខេត្តបន្ទាយមានជ័យ ហៅកាត់ថាគម្រោង PRDB**
**គម្រោងគាំទ្រការស្តាបនាឡើងវិញជាមួយការបោសសម្អាតគ្រាប់បែកចង្កោមនៅខេត្តស្ទឹងត្រែង ហៅកាត់ថាគម្រោង PRCS**
**អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS)**

សូមគោរព
- **លោកបណ្ឌិត អីវ៉ាណូ ស៊ុហ្គោយ៉ីគិ** ប្រធានតំណាងអង្គការ JMAS ប្រចាំប្រទេសកម្ពុជា
- លោក លោកស្រី ភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី។

សួស្តីអ្នកទាំងអស់គ្នា។
ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានរៀបចំពិធីចុះហត្ថលេខាលើគម្រោងចំនួន២នៃជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុននាថ្ងៃនេះ។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលហៅថា “អ៊ិនរ៉េន” បានចាប់ផ្តើមតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ពួកគេនៅក្នុងប្រទេស ឬតំបន់កំពុងអភិវឌ្ឍ។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុនបានផ្តល់ជំនួយជាង ១៦០គម្រោង នៅក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីនេះ ហើយគម្រោងទាំងនេះបានចូលរួមចំណែកដោយផ្ទាល់ក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជា។

ខ្ញុំសូមជម្រាបជូនដោយសង្ខេបអំពីគម្រោងចំនួន២ ដែលយើងបានចុះហត្ថលេខានាថ្ងៃនេះៈ

រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកា ប្រមាណ ៦៥០,០០០ ដុល្លារអាមេរិក សម្រាប់គម្រោងចំនួន២ ឬជាសរុបប្រមាណ ១,៣០០,០០០ ដុល្លារអាមេរិក ដែលអង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS) នឹងអនុវត្តក្នុងខេត្តបន្ទាយមានជ័យ និងខេត្តស្ទឹងត្រែង។

ចាប់តាំងពីឆ្នាំ២០០២មក អង្គការ JMAS បានចូលរួមក្នុងសកម្មភាពគាំទ្រការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅកម្ពុជា ជាមួយមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC)។ ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងការគោរពយ៉ាងជ្រាលជ្រៅចំពោះការងារដ៏សំខាន់ៗដែលអង្គការសម្រេចបាន។

សម្រាប់គម្រោងទាំងពីរនេះ បន្ថែមលើការបោសសម្អាតគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះក្នុងខេត្តបន្ទាយមានជ័យ និងគ្រាប់បែកចង្កោមក្នុងខេត្តស្ទឹងត្រែង អង្គការ JMAS នឹងបន្តផ្តល់ការអប់រំអំពីការជៀសវាងពីគ្រោះថ្នាក់ និងផ្តល់ជំនួយផ្នែកកសិកម្ម។ យើងសង្ឃឹមថា គម្រោងទាំងពីរដែលបានចុះហត្ថលេខានៅថ្ងៃនេះ នឹងកាត់បន្ថយការរងទុក្ខរបស់មនុស្សដែលបណ្តាលមកពីគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់

ផ្ទះ ធ្វើឱ្យការរស់នៅរបស់ប្រជាជនក្នុងតំបន់រងគ្រោះមានសុខសន្តិភាព នឹងភាពប្រសើរជាងមុន ព្រមទាំងរួមចំណែកក្នុងការសម្រេចបាននូវការបោសសម្អាតគ្រាប់មីនប្រឆាំងមនុស្ស ដែលជាគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំមានសេចក្ដីសោមនស្សរីករាយដោយសង្កេតឃើញថានាពេលថ្មីៗនេះ ប្រទេសកម្ពុជាបាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជន ដែលរួមមាន ការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ក៏ដូចជាការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម ដូចជា សុខភាព ការអប់រំ និងបរិស្ថានផងដែរ។ រដ្ឋាភិបាលជប៉ុន នឹងបន្តសហការជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិរបស់ជប៉ុន ក្នុងការដោះស្រាយបញ្ហានានា។

ជាទីបញ្ចប់នៃការថ្លែងសន្ទរកថារបស់ខ្ញុំ ខ្ញុំសូមឱ្យគម្រោងទាំង២ ដែលចុះហត្ថលេខានាថ្ងៃនេះដំណើរការទៅដោយរលូន និងទទួលបានភាពជោគជ័យនាពេលអនាគត។ ហើយខ្ញុំសូមជូនពរ លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និង សូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណច្រើន។